**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ១៧០ ប្រក កសក

# ប្រកាស

## ស្ដីពី

## ការគ្រប់គ្រងសកម្មភាពជីកកាស់ ជីកជញ្ជូន និង ធ្វើអាជីវកម្ម រុក្ខជាតិ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការ រៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០១/៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពី ការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ១ ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia Phone (023) 726 128 / 726 129 Fax . (855) 23 217 320

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១៤៩ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៥ ស្ដីពីការកំណត់ប្រភេទសត្វ និង រុក្ខជាតិសម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក.ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្ដីពីការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកេសិត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្ដីពីការត្រួតពិនិត្យភូតគាមអនាម័យ
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦ ស្ដីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និង រុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**ប្រការ ១ :**

ប្រកាសនេះមានគោលបំណងកំណត់នូវបទបញ្ញា ក្នុងការគ្រប់គ្រងសកម្មភាពជីកកាស់ ដឹកជញ្ជូន និង ធ្វើអាជីវកម្មគ្រប់រូបភាពនូវបណ្ដាប្រភេទរុក្ខជាតិ ឬ ដើមឈើ ដែលមានអាយុកាលយូរលង់ ហើយមានសារសំខាន់ក្នុងប្រវត្តិសាស្ត្រ វប្បធម៌ ជំនឿសាសនា ប្រពៃណីជាតិ និង មានតម្លៃជាសម្បត្តិ ឬ មរតក ធម្មជាតិរួមរបស់ជាតិ ហៅកាត់ថា "រុក្ខជាតិ" ក្នុងគោលដៅចូលរួមថែរក្សា ការពារ និង អភិរក្ស ធនធានជីវចម្រុះរបស់ជាតិ។

**ប្រការ ២ :**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ គ្រប់សកម្មភាពរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលពាក់ព័ន្ធនឹងការជីកកាស់ ការដឹកជញ្ជូន ការធ្វើអាជីវកម្មគ្រប់រូបភាពនូវបណ្ដាប្រភេទរុក្ខជាតិ ឬ ដើមឈើ ដូចមានចែងក្នុងប្រការ ១ នៃប្រកាសនេះ ក្នុងព្រះរាជាណាចក្រកម្ពុជា។

២

ប្រការ ៣ :

ការដឹកជញ្ជូន "រុក្ខជាតិ" ដែលមានអាយុកាលយូរលង់ និង មានទ្រង់ទ្រាយដើមទាំងស្រុង ដោយបានមកពីការជីកកាស់ចេញពីគ្រប់ទីតាំងនៃប្រភពដើម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានហាមឃាត់។

ប្រការ ៤ :

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងជីកកាស់ "រុក្ខជាតិ" ដែលមានអាយុកាលយូរលង់ ដើម្បីដឹកជញ្ជូនយកមកធ្វើការដាំលម្អ ឬ បំប៉នដើម្បីដាំលម្អ ដែលមានទីតាំង និងគម្រោងជាក់លាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំការអនុញ្ញាតជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

ប្រការ ៥ :

ការធ្វើអាជីវកម្មគ្រប់រូបភាព ជាពិសេស ការនាំចេញ "រុក្ខជាតិ" ដែលមានអាយុកាលយូរលង់ និង មានទ្រង់ទ្រាយដើមទាំងស្រុង ដោយបានមកពីការជីកកាស់ចេញពីគ្រប់ទីតាំងនៃប្រភពដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានហាមឃាត់។

ប្រការ ៦ :

ការធ្វើអាជីវកម្មគ្រប់រូបភាព ឬ ការធ្វើសន្និធិនៅក្នុងសួន សម្រាប់លក់ចែកចាយនូវបណ្ដា "រុក្ខជាតិ" អាចប្រព្រឹត្តទៅបាន លុះត្រាតែ "រុក្ខជាតិ" ទាំងនោះបានមកពីការធ្វើពហុកម្ម ឬ ពង្រីកកូន ហើយត្រូវមានលិខិតអនុញ្ញាតធ្វើអាជីវកម្មចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

ប្រការ ៧ :

រាល់សកម្មភាពដឹកជញ្ជូន ឬ ធ្វើអាជីវកម្ម នូវពូជ "រុក្ខជាតិ" ដែលដាក់តាំងលក់ ឬ ធ្វើពហុកម្មសម្រាប់លក់ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និង អនុវត្តច្បាប់ ដោយមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

ប្រការ ៨ :

រាល់សកម្មភាពជីកកាស់ ដឹកជញ្ជូន និង ធ្វើអាជីវកម្មគ្រប់រូបភាព នូវបណ្ដា "រុក្ខជាតិ" ទាំងឡាយដែលមានប្រភព ឬ ស្ថិតនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និង តំបន់គ្រប់គ្រងជលផល ត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ និង ច្បាប់ស្តីពី ជលផលជាធរមាន។

៣

**ប្រការ ៩ :**

ជនណាដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន។

**ប្រការ ១០ :**

បទបញ្ជា ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១១ :**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ ប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមិនា ឆ្នាំ ២០១១

**រដ្ឋមន្ត្រី**

**ចាន់ សារុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-សាលារាជធានី ខេត្ត
-ដូចប្រការ ១១
-ឯកសារ-កាលប្បវត្តិ